# សេចក្តីថ្លែងការណ៍រួម
# រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន
# ស្តីពីការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន គ្រប់រដូវកាល ក្នុងយុគសម័យថ្មី និងការអនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍសកល គំនិតផ្តួចផ្តើមសន្តិសុខសកល និង គំនិតផ្តួចផ្តើមអរិយធម៌សកល

តបតាមការអញ្ជើញរបស់**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិតចិនបាន អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី១៧ ដល់ ១៨ ខែមេសា ឆ្នាំ២០២៥។ ក្នុងដំណើរទស្សនកិច្ចនេះ **ឯកឧត្តម ស៊ី ជីនពីង** បានចូលថ្វាយបង្គំគាល់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ហើយជួបពិភាក្សាជាមួយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាមួយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ភាគីទាំងពីរបានបញ្ជាក់ជាថ្មីថា កម្ពុជា និងចិន ជាមិត្តដែកថែប ដែលជឿទុកចិត្តគ្នាទៅវិញទៅមក និងគាំទ្រគ្នាគ្រប់កាលៈទេសៈ។ ចំណងមិត្តភាពជាប្រពៃណីកម្ពុជា-ចិន ត្រូវបានពូនជ្រំ និងថែរក្សាយ៉ាងយកចិត្តទុកដាក់ដោយ**ព្រះករុណា ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ** និងថ្នាក់ដឹកនាំចិនជំនាន់មុន ដែលជាជម្រើសប្រវត្តិសាស្ត្រ និងរបស់ប្រជាជនទាំងពីរ។ ជាយូរមកហើយ ភាគីទាំងពីរបានបន្តប្តេជ្ញារក្សាសមភាព ផលប្រយោជន៍ទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ ហើយគាំទ្រគ្នាទៅវិញទៅមកយ៉ាងពេញទំហឹង ក្នុងការការពារអធិបតេយ្យ សន្តិសុខ និងផលប្រយោជន៍អភិវឌ្ឍន៍របស់ជាតិ ព្រមទាំងរួមគ្នាការពារសច្ចធម៌ និងយុត្តិធម៌អន្តរជាតិ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសក្រោមការដឹកនាំប្រកបដោយយុទ្ធសាស្ត្ររបស់**ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** និងថ្នាក់ដឹកនាំកម្ពុជា ប្រទេសទាំងពីរបានឯកភាពគ្នាកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី ប្រកបដោយគុណភាពខ្ពស់ កម្រិតខ្ពស់ និងស្តង់ដាខ្ពស់ ជាមួយនឹងការបន្តពង្រឹងទំនុកចិត្តគ្នាជាយុទ្ធសាស្ត្រ កិច្ចសហប្រតិបត្តិការផ្លែផ្កាជាក់ស្តែង ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជនកាន់តែញឹកញាប់ និងកិច្ចសហប្រតិបត្តិការពហុភាគីកាន់តែជិតស្និទ្ធ បង្កើតគំរូល្អថ្មីនៃទំនាក់ទំនងអន្តរជាតិ និងសហគមន៍វាសនារួមសម្រាប់មនុស្សជាតិ។

ប្រឈមនឹងការប្រែប្រួលរបស់ពិភពលោក តាមពេលវេលា និងរបត់ប្រវត្តិសាស្ត្រ ភាគីទាំងពីរបានឯកភាពពន្លឿនការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន គ្រប់រដូវកាល ក្នុងយុគសម័យថ្មី។ ក្រោមការឯកភាពជាយុទ្ធសាស្ត្រកម្រិតខ្ពស់រវាងប្រទេសទាំងពីរ ដោយមានគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ជាយន្តការគ្រប់គ្រងរួម និងការអនុវត្តផែនការសកម្មភាព ស្តីពីការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី ជាចំណុចចម្បង ភាគីទាំងពីរនឹងបន្តជំរុញក្របខណ្ឌកិច្ចសហ

ប្រតិបត្តិការត្បូងពេជ្រកម្ពុជា-ចិន ដែលមានវិស័យអាទិភាពចំនួន ០៦ និងពន្លឿនការកសាង «ច្រករបៀងឧស្សាហកម្ម និងបច្ចេកវិទ្យា» និង «ច្រករបៀងមច្ឆា និងអង្ករ» ព្រមទាំងពង្រឹងទំនុកចិត្តនយោបាយកាន់តែខ្ពស់ ពង្រីកកិច្ចសហប្រតិបត្តិការផ្តល់ផលប្រយោជន៍ទៅវិញទៅមកប្រកបដោយគុណភាពខ្ពស់ ធានាសន្តិសុខកម្រិតខ្ពស់ ការផ្លាស់ប្តូរឱ្យបានញឹកញាប់រវាងប្រជាជននិងប្រជាជន និងពង្រឹងកិច្ចសម្របសម្រួលជាយុទ្ធសាស្ត្រប្រកបដោយស្តង់ដាខ្ពស់។

ភាគីកម្ពុជាវាយតម្លៃខ្ពស់ចំពោះការផ្តួចផ្តើមរបស់**ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** រួមមានការកសាងសហគមន៍វាសនារួមសម្រាប់មនុស្សជាតិ គំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល គំនិតផ្តួចផ្តើមសន្តិសុខសកល និងគំនិតផ្តួចផ្តើមអរិយធម៌សកល។ ភាគីកម្ពុជាជឿជាក់ថា គំនិតផ្តួចផ្តើមទាំងនេះ នឹងនាំមកនូវការការពារផលប្រយោជន៍រួមរបស់មនុស្សជាតិ ការលើកកម្ពស់បុព្វហេតុសន្តិភាព យុត្តិធម៌ និងវឌ្ឍនភាពរបស់ប្រជាជនទូទាំងសកលលោក ហើយឆ្លុះបញ្ចាំងពីបំណងប្រាថ្នារួមសម្រាប់ពិភពលោកមួយល្អប្រសើរ។ ភាគីទាំងពីរនឹងបន្តប្រឹងប្រែងជំរុញការអនុវត្តគំនិតផ្តួចផ្តើមទាំងនេះ និងរួមចំណែកជាវិជ្ជមានក្នុងការរក្សា និងលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់ និងពិភពលោក។

## ការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន គ្រប់រដូវកាល ក្នុងយុគសម័យថ្មី

១. ភាគីទាំងពីរសង្កត់ធ្ងន់ថា ការផ្លាស់ប្តូរកម្រិតខ្ពស់មានសារៈសំខាន់ចំពោះការអភិវឌ្ឍទំនាក់ទំនងកម្ពុជា-ចិន និងបន្តរក្សាការផ្លាស់ប្តូរកម្រិតខ្ពស់ ប្រើប្រាស់គណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ហើយពង្រឹងការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល ស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។ ភាគីទាំងពីរនឹងពង្រឹងកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាមានសមត្ថកិច្ចពាក់ព័ន្ធនៃប្រទេសទាំងពីរ ជំរុញការផ្លាស់ប្តូរបទពិសោធន៍អភិបាលកិច្ច និងគាំទ្រការបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលនិងការគ្រប់គ្រងដោយប្រើប្រាស់ព័ត៌មានវិទ្យា ក្នុងគោលដៅលើកកម្ពស់ទំនើបភាវូបនីយកម្មរបស់ប្រទេសរៀងខ្លួន។

ភាគីទាំងពីរបានសម្រេចបង្កើតយន្តការកិច្ចសន្ទនាយុទ្ធសាស្ត្រ ២+២ កម្រិតរដ្ឋមន្ត្រីការបរទេស និងរដ្ឋមន្ត្រីការពារជាតិ ដើម្បីសម្របសម្រួលជំហរលើការប្រឈមជាយុទ្ធសាស្ត្រចម្បងៗឱ្យបានទាន់ពេលវេលា និងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងវិស័យពាក់ព័ន្ធ។

២. ភាគីកម្ពុជាវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលជាប្រវត្តិសាស្ត្រ នៃការអភិវឌ្ឍរបស់ចិនក្នុងយុគសម័យថ្មី ហើយជឿជាក់ថា ទំនើបភាវូបនីយកម្មរបស់ចិនផ្តល់នូវជម្រើសមាគ៌ា និងផ្តល់ដំណោះស្រាយជាក់ស្តែងដល់ទំនើបភាវូបនីយកម្មរបស់មនុស្សជាតិ។ ភាគីកម្ពុជាគាំទ្រយ៉ាងពេញទំហឹងចំពោះចិនក្នុងការកសាងប្រទេសសង្គមនិយមទំនើបដ៏អស្ចារ្យ និងប្រជាជាតិចិនដ៏រុងរឿងគ្រប់វិស័យ តាមរយៈមាគ៌ាទំនើបភាវូបនីយកម្មរបស់ចិន។ ភាគីចិនវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលគួរឱ្យកត់សម្គាល់របស់កម្ពុជា ក្នុងការរក្សាស្ថិរភាពនយោបាយ ការជំរុញកំណើនសេដ្ឋកិច្ច ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងកេរ្តិ៍ឈ្មោះកម្ពុជាលើឆាកអន្តរជាតិ ព្រមទាំងគាំទ្ររាជរដ្ឋាភិបាលកម្ពុជាយ៉ាងពេញទំហឹងក្នុងការអនុវត្តដោយរលូននូវ

អភិបាលកិច្ច និងការសម្រេចនូវគោលដៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ភាគីទាំងពីរបានឯកភាពគ្នាលើកកម្ពស់ការបន្សុីគ្នារវាងគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ និងយុទ្ធសាស្ត្របញ្ចកោណ ព្រមទាំងអនុវត្តចំណុចនៃផែនការកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីរួមគ្នាបង្កើតកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្លូវសូត្រ និងកិច្ចសហប្រតិបត្តិការផ្លូវសូត្រសមុទ្រសតវត្សទី២១ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន និងបង្កើតគម្រោងកិច្ចសហប្រតិបត្តិការផ្សេងៗបន្ថែមទៀត។

៣. ភាគីទាំងពីរបញ្ជាក់ជាថ្មីនូវការគាំទ្រផលប្រយោជន៍ស្នូល អធិបតេយ្យភាពជាតិ និងបូរណភាពទឹកដីរបស់គ្នាទៅវិញទៅមក ព្រមទាំងប្រឆាំងដាច់ខាតចំពោះការជ្រៀតជ្រែករបស់បរទេសក្នុងកិច្ចការផ្ទៃក្នុងប្រទេសនីមួយៗ។

ភាគីកម្ពុជាបញ្ជាក់ជាថ្មីនូវការប្រកាន់ខ្ជាប់ «គោលនយោបាយចិនមួយ» ហើយសិទ្ធិអំណាចនៃសេចក្តីសម្រេចចិត្តលេខ ២៧៥៨ របស់មហាសន្និបាតអង្គការសហប្រជាជាតិ មិនគួរមានជាចំណោទ ឬបញ្ហាប្រឈមឡើយ។ ភាគីកម្ពុជាទទួលស្គាល់ថាគឺមានចិនតែមួយលើពិភពលោក ហើយបញ្ជាក់ថារដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជារដ្ឋាភិបាលស្របច្បាប់តែមួយគត់តំណាងឱ្យប្រទេសចិនទាំងមូល រីឯតៃវ៉ាន់គឺជាផ្នែកមួយមិនអាចកាត់ផ្តាច់ចេញពីទឹកដីរបស់ចិនបានឡើយ។ កម្ពុជាគាំទ្រម៉ឺងម៉ាត់រាល់កិច្ចខិតខំប្រឹងប្រែងរបស់ចិនក្នុងការសម្រេចនូវការបង្រួបបង្រួមជាតិ ប្រឆាំងដាច់ខាតនូវ «ឯករាជ្យភាពតៃវ៉ាន់» និងមិនបង្កើតទំនាក់ទំនងផ្លូវការជាមួយតៃវ៉ាន់ ក្នុងទម្រង់ណាមួយក៏ដោយ។ ភាគីកម្ពុជាប្រឆាំងការយកបញ្ហាតៃវ៉ាន់ ស៊ីនជាំង ស៊ីចាង និងហុងកុង ជាលេសក្នុងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង ឬរារាំងចិន។ ភាគីទាំងពីរមិនអនុញ្ញាតអោយមានសកម្មភាពអមិត្តប្រឆាំងនឹងរដ្ឋនីមួយៗកើតមាននៅលើទឹកដីរបស់ខ្លួនឡើយ។

ភាគីចិនបញ្ជាក់ជាថ្មីនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះកម្ពុជាក្នុងការប្រកាន់មាគ៌ាអភិវឌ្ឍន៍ដោយឯករាជ្យ និងស្របតាមលក្ខខណ្ឌជាតិរបស់កម្ពុជា ព្រមទាំងគាំទ្រកម្ពុជាដោយឥតងាករេចំពោះការការពារអធិបតេយ្យភាពជាតិ ឯករាជ្យភាព និងបូរណភាពទឹកដី ព្រមទាំងតួនាទីកាន់តែសកម្ម និងសំខាន់របស់កម្ពុជាក្នុងកិច្ចការតំបន់ និងអន្តរជាតិ។

៤. ដោយឆ្នាំ២០២៥ ជាខួប ៨០ឆ្នាំ នៃការបង្កើតអង្គការសហប្រជាជាតិ ភាគីទាំងពីរបញ្ជាក់ជាថ្មីនូវការប្តេជ្ញាប្រកាន់ខ្ជាប់ប្រព័ន្ធអន្តរជាតិដែលមានអង្គការសហប្រជាជាតិជាស្នូល សណ្តាប់ធ្នាប់អន្តរជាតិផ្អែកលើច្បាប់អន្តរជាតិ និងបទដ្ឋានជាមូលដ្ឋាននៃទំនាក់ទំនងអន្តរជាតិ ស្របតាមគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ ភាគីទាំងពីរប្រឆាំងអនុត្តរភាព និងឯកតោភាគីនិយមគ្រប់ទម្រង់ ហើយអំពាវនាវឱ្យមានការស្តារឡើងវិញនូវពហុភាគីនិយមពិតប្រាកដ និងប្រជាធិបតេយ្យក្នុងទំនាក់ទំនងអន្តរជាតិ ដើម្បីរួមគ្នាការពារសេចក្តីធម៌ និងយុត្តិធម៌អន្តរជាតិ ព្រមទាំងផលប្រយោជន៍រួមរបស់ប្រជាជាតិទាំងអស់។ ភាគីទាំងពីរគាំទ្រពិភពលោកពហុប៉ូលប្រកបដោយសមភាព និងសណ្តាប់ធ្នាប់ និងសកលភាវូបនីយកម្មសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ននិងផលប្រយោជន៍ជាសកល ដើម្បីកសាងប្រព័ន្ធអភិបាលកិច្ចសកលប្រកបដោយយុត្តិធម៌ និងសមធម៌។

៥. ភាគីទាំងពីរសង្កត់ថា ឆ្នាំ២០២៤ ជាខួប ៧០ ឆ្នាំ នៃគោលការណ៍ ៥ នៃសន្តិសហវិជ្ជមាន ហើយ ឆ្នាំ២០២៥ ជាខួប ៧០ឆ្នាំ នៃសន្និសីទទីក្រុងបានឌុង។ គោលការណ៍៥ នៃសន្តិសហវិជ្ជមាន និងស្មារតី នៃសន្និសីទទីក្រុងបានឌុងបានឆ្លងកាត់ពេលវេលាប្រឈមជាច្រើន ហើយវិវត្តទៅជាបទដ្ឋានមូលដ្ឋាននៃ ទំនាក់ទំនងអន្តរជាតិ ដែលបើកចំហ បរិយាប័ន្ន អនុវត្តបានជាសកល និងជាគោលការណ៍ នៃច្បាប់អន្តរជាតិ ដែលបានរួមចំណែកជាប្រវត្តិសាស្ត្រ និងជាសកល។ ភាគីកម្ពុជាសាទរភាគីចិនចំពោះជោគជ័យក្នុងការធ្វើ ជាម្ចាស់ផ្ទះ នៃសន្និសីទរំលឹកខួប៧០ ឆ្នាំ នៃគោលការណ៍៥នេះ កាលពីឆ្នាំមុន។ ភាគីទាំងពីរបានឯកភាព ប្រកាន់ខ្ជាប់គោលការណ៍ ៥ នៃសន្តិសហវិជ្ជមាន លើកកម្ពស់តម្លៃអាស៊ី ដែលផ្តោតលើសន្តិភាព កិច្ចសហ ប្រតិបត្តិការ បរិយាប័ន្ន និងសមាហរណកម្ម ព្រមទាំងគាំទ្រស្មារតីរួបរួមគ្នា មិត្តភាព និងកិច្ចសហប្រតិបត្តិការ នៃសន្និសីទទីក្រុងបានឌុង ដើម្បីរួមគ្នាកសាងសហគមន៍វាសនារួមសម្រាប់មនុស្សជាតិ។

ភាគីទាំងពីរបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាអនុវត្តតំបន់បើកចំហ គាំទ្រអាស៊ានរក្សាឯករាជ្យភាព យុទ្ធសាស្ត្រ លើកកម្ពស់មជ្ឈភាពអាស៊ាននិងកសាងតំបន់ប្រកបដោយសន្តិភាព សុវត្ថិភាព សន្តិសុខ វិបុលភាព សោភ័ណភាព និងមិត្តភាព ដើម្បីលើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ចិន និង ជំរុញសហគមន៍វាសនារួមអាស៊ាន-ចិនឱ្យកាន់តែជិតស្និទ្ធ។ ភាគីទាំងពីរបានឯកភាពគ្នាពន្លឿនការកសាង សហគមន៍វាសនារួម នៃសន្តិភាព និងវិបុលភាព ក្នុងបណ្តាប្រទេសមេគង្គ-ឡានឆាង និងជានាជោគជ័យ នៃកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង លើកទី៥ និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ឡានឆាង លើកទី១០ ។

## ការអនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល (GDI)

ភាគីទាំងពីរបានគូសបញ្ជាក់ពីការប្តេជ្ញាប្រកាន់ខ្ជាប់ទស្សនៈអភិវឌ្ឍន៍ផ្តោតលើប្រជាជន ផ្តល់អាទិភាព ដល់ការអភិវឌ្ឍ និងជីវភាពរស់នៅរបស់ប្រជាជន ហើយធ្វើជាអ្នកនាំមុខនៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល។ ភាគីទាំងពីរនឹងជំរុញវឌ្ឍនភាពសំខាន់ៗ នៃគំនិតផ្តួចផ្តើមនេះ ក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគី ដើម្បីផ្តល់ សន្ទុះដល់ការអភិវឌ្ឍរួមក្នុងពិភពលោក ជាពិសេសបណ្តាប្រទេសលោកខាងត្បូង។

១. ភាគីទាំងពីរឯកភាពថា ការរឹតបន្តឹងលើពាណិជ្ជកម្ម និងការវិនិយោគបានបង្កផលប៉ះពាល់លើ សន្តិសុខសេដ្ឋកិច្ចនិងសណ្តាប់ធ្នាប់ពាណិជ្ជកម្មអន្តរជាតិ និងប្រឆាំងដាច់ខាតចំពោះពាណិជ្ជកម្មគាំពារ និយម។ ភាគីទាំងពីរបញ្ជាក់នូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដែល មានអង្គការពាណិជ្ជកម្មពិភពលោកជាស្នូល អាចព្យាករណ៍បាន ផ្អែកលើច្បាប់ បើកចំហ មានតម្លាភាព បរិយាប័ន្ន និងមិនរើសអើង។ ភាគីទាំងពីរទទួលស្គាល់នូវសារៈសំខាន់នៃអង្គការពាណិជ្ជកម្មពិភពដែលជា វេទិកាសម្រាប់ពិភាក្សាលើការបង្កើតវិធានច្បាប់ពាណិជ្ជកម្ម ការសន្ទនានិងកិច្ចសហប្រតិបត្តិការ និងទទួល ស្គាល់តួនាទីស្នូលរបស់អង្គការនេះក្នុងការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ការវិនិយោគ និងការសម្រប សម្រួល ព្រមទាំងការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់ប្រទេសទាំងអស់។ ភាគីទាំងពីរបាន ត្រៀមខ្លួនចូលរួមជំរុញកំណែទម្រង់អង្គការនេះ និងត្រៀមធ្វើការរួមគ្នាដើម្បីទទួលបានលទ្ធផលជាក់ស្តែង នៃសន្និសីទអង្គការពាណិជ្ជកម្មពិភពថ្នាក់រដ្ឋមន្ត្រីលើកទី១៤ ដើម្បីជំរុញសកលភាវូបនីយកម្មសេដ្ឋកិច្ច

កាន់តែបើកចំហ បរិយាប័ន្ន តុល្យភាព និងផលប្រយោជន៍សម្រាប់ទាំងអស់គ្នា។

២. ភាគីទាំងពីរបានឯកភាពពន្លឿនផែនការ «ច្រករបៀងឧស្សាហកម្ម និងបច្ចេកវិទ្យា» ដើម្បីវឌ្ឍនភាពជាដុំកំភួន និងអនុវត្តកិច្ចសហប្រតិបត្តិការឧស្សាហកម្ម និងវិនិយោគកម្ពុជា-ចិន ដែលមានគុណភាពខ្ពស់ ព្រមទាំងអនុវត្តគម្រោងវិនិយោគសំខាន់ៗ។

៣. ភាគីទាំងពីរបានឯកភាពផ្តល់តួនាទីសំខាន់ដល់យន្តការសហប្រតិបត្តិការផ្លូវដែកកម្ពុជា-ចិន ដើម្បីធ្វើការរួមគ្នាបង្កើតផែនការរួម សម្រាប់បណ្តាញផ្លូវដែកកម្ពុជា និងកំណត់គម្រោងសំខាន់ៗ។ ភាគីទាំងពីរបានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការលើយន្តហោះពាណិជ្ជកម្ម និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្សេងៗ។ ភាគីចិនគាំទ្រកម្ពុជាអភិវឌ្ឍ «គម្រោងគ្រប់គ្រងធនធានទឹកចម្រុះហ្វូណនតេជោ» ក្រោមគោលការណ៍សមិទ្ធិលទ្ធភាព និងនិរន្តរភាព។

៤. ភាគីទាំងពីរកោតសរសើរលទ្ធផលនៃកិច្ចប្រជុំលើកទី១ នៃ «ច្រករបៀងមច្ឆា និងអង្ករ» និងឯកភាពពន្លឿនការអនុវត្តផែនការកិច្ចសហប្រតិបត្តិការលើច្រករបៀងនេះ ដើម្បីទទួលលទ្ធផលជាក់ស្តែង និងជំរុញឱ្យមានវឌ្ឍនភាពប្រសើរក្នុងកិច្ចសហប្រតិបត្តិការផ្ទេរបច្ចេកវិទ្យា ពាណិជ្ជកម្ម និងការវិនិយោគលើវិស័យកសិកម្មរវាងប្រទេសទាំងពីរ។

៥. ភាគីទាំងពីរបានឯកភាពបន្តផ្តល់តួនាទីដល់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(អាសិប) កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងជំរុញការចុះហត្ថលេខាឲ្យបានឆាប់លើពិធីសារដំឡើងកម្រិតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ៣.០ ក្នុងឆ្នាំនេះ ហើយពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យកំពុងលេចធ្លោ និងបង្កើនទំហំពាណិជ្ជកម្ម។ ភាគីកម្ពុជាគាំទ្រតំបន់រដ្ឋបាលពិសេសហុងកុង ចូលជាសមាជិកអាសិប។ ភាគីទាំងពីរត្រៀមខ្លួនជាស្រេចដើម្បីពន្លឿនកិច្ចសហប្រតិបត្តិការច្រកចេញចូលតែមួយ និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតយន្តការរយៈពេលវែង ហើយជំរុញការចរចា និងការចុះហត្ថលេខាលើពិធីសារចត្តាឡីស័កសម្រាប់ការនាំចេញនូវកសិផលនិងចំណីអាហារបន្ថែមដែលមានគុណភាពរបស់កម្ពុជាទៅកាន់ប្រទេសចិន។

៦. ភាគីទាំងពីរបានឯកភាពកសាងខ្សែច្រវាក់ផ្គត់ផ្គង់និងឧស្សាហកម្មប្រកបដោយសុវត្ថិភាព និងស្ថិរភាព គាំទ្រការអភិវឌ្ឍតំបន់សហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មប្រកបដោយស្តង់ដាខ្ពស់ ជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន បណ្តាញអគ្គិសនី និងខ្សែកាបអុបទិក ប្រព្រឹត្តកម្មទឹកកខ្វក់ ឃ្លាំង និងភស្តុភារកម្ម។ ភាគីចិននឹងបន្តគាំទ្រដល់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ឆ្ពោះទៅរកចក្ខុវិស័យនៃការអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណងគំរូ និងលើកទឹកចិត្តក្រុមហ៊ុនចិនដែលមានសមត្ថភាពឱ្យបង្កើនការវិនិយោគនៅកម្ពុជា។

៧. ភាគីទាំងពីរបានឯកភាពពង្រីកការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុកសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគទ្វេភាគី ព្រមទាំងគាំទ្រការចូលរួមរវាងធនាគារពាណិជ្ជនានារបស់កម្ពុជាជាមួយនឹងប្រព័ន្ធទូទាត់

ប្រាក់យ៉ែនអន្តរធនាគារឆ្លងដែន និងឯកភាពគ្នាជំរុញកិច្ចសហការក្នុងការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែន តាមរយៈ QR កូដ។

៨. ភាគីទាំងពីរបានប្តេជ្ញាលើកកម្ពស់កិច្ចសហប្រតិបត្តិការថាមពលស្អាត រួមមានគម្រោងវារីអគ្គិសនី ស្ថានីយ៍វារីអគ្គិសនីបូមទឹកស្តុកទុក ថាមពលពន្លឺព្រះអាទិត្យ ថាមពលដើរដោយខ្យល់ និងបច្ចេកវិទ្យា ថាមពលស្អាតផ្សេងៗ។ ភាគីទាំងពីរបានប្តេជ្ញាជួយគ្នាទៅវិញទៅមកក្នុងកិច្ចសហប្រតិបត្តិការថាមពល តំបន់ និងសកល។

៩. ភាគីទាំងពីរបានត្រៀមខ្លួនអនុវត្តកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងផ្តល់តួនាទីកាន់តែសំខាន់ដល់គណៈកម្មាធិការចម្រុះ ស្តីពីកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រវាងរដ្ឋាភិបាលទាំងពីរ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវរួមគ្នា ការផ្ទេរបច្ចេកវិទ្យា នវានុវត្តន៍ និងសហគ្រិនភាព ព្រមទាំងជំរុញកម្លាំងផលិតកម្មថ្មី ប្រកបដោយគុណភាព។ ភាគីទាំងពីរឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យទំនើបចុងក្រោយ រួមមានសេដ្ឋកិច្ចឌីជីថល និង សកម្មភាពសេដ្ឋកិច្ចក្នុងដែនរយៈកម្ពស់ទាប( low-altitude economy )។

១០. ភាគីកម្ពុជាស្វាគមន៍គំនិតផ្តួចផ្តើមអភិបាលកិច្ចបញ្ញាសិប្បនិម្មិតសកល ដែលផ្តួចផ្តើមដោយ ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង។ ភាគីចិនស្វាគមន៍កម្ពុជាចូលរួម និងដើរតួនាទីសកម្មក្នុងក្រុមមិត្តភាព ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ លើការអភិវឌ្ឍន៍បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត។

១១. ភាគីកម្ពុជាវាយតម្លៃខ្ពស់ចំពោះជំនួយដ៏មានសារៈសំខាន់របស់ភាគីចិន ក្នុងការលើកកម្ពស់ការ អភិវឌ្ឍន៍សេដ្ឋកិច្ច និងការធ្វើឱ្យប្រសើរនូវជីវភាពប្រជាជនកម្ពុជា។ ភាគីទាំងពីរនឹងផ្តល់តួនាទីកាន់តែ សំខាន់ដល់យន្តការកិច្ចសន្ទនា ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា-ចិន និងរៀបចំផែនការកិច្ចសហ ប្រតិបត្តិការអភិវឌ្ឍន៍ ព្រមទាំងបន្តអនុវត្តគម្រោងនានាដូចជា ផ្លូវជនបទ ការផ្គត់ផ្គង់ទឹក សាលារៀន មន្ទីរ ពេទ្យ និងការកាត់បន្ថយភាពក្រីក្រ និងការគាំទ្រដល់ក្រុមការងាររបស់ព្រះមហាក្សត្រ តាមរយៈគម្រោង ជាក់ស្តែងបន្ថែមទៀត។

១២. ភាគីទាំងពីរបានទទួលស្គាល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលកំពុងគំរាម កំហែងពិភពលោក ប៉ះពាល់ដល់ជីវិតមនុស្ស និងសត្វ ហើយបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការអភិរក្ស និងការការពារធនធានធម្មជាតិ។ ភាគីទាំងពីរនឹងពង្រឹងកិច្ចសហប្រតិបត្តិការលើការការពារបរិស្ថាន និង បន្តជំរុញការកសាងតំបន់បង្ហាញការបញ្ចេញកាបូនទាបកម្ពុជា-ចិន នៅខេត្តព្រះសីហនុ ក្រោមក្របខណ្ឌ កិច្ចសហប្រតិបត្តិការត្បូង-ត្បូង ស្តីពីការប្រែប្រួលអាកាសធាតុ ។

**ការអនុវត្តគំនិតផ្តួចផ្តើមសន្តិសុខសកល (GSI)**

ភាគីទាំងពីរគាំទ្រចក្ខុវិស័យសន្តិសុខរួម គ្រប់ជ្រុងជ្រោយ ប្រកបដោយកិច្ចសហប្រតិបត្តិការ និងចីរភាព

ព្រមទាំងគោរពអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី គោលបំណងនិងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ ភាគីទាំងពីរយកចិត្តទុកដាក់ខ្លាំងលើការព្រួយបារម្ភសន្តិសុខស្របច្បាប់របស់ប្រទេសទាំងអស់ ការដោះស្រាយជម្លោះនិងការមិនចុះសម្រុងគ្នាដោយសន្តិវិធី តាមរយៈកិច្ចសន្ទនា និងការពិគ្រោះយោបល់ និងការថែរក្សាសន្តិសុខប្រពៃណី និងមិនប្រពៃណី តាមរយៈការសម្របសម្រួល។ ភាគីទាំងពីរនឹងធ្វើការរួមគ្នាអនុវត្តគំនិតផ្តួចផ្តើមសន្តិសុខសកល ជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែង និងរួមចំណែកជាវិជ្ជមានដល់សន្តិភាព និងស្ថិរភាពតំបន់ និងសកល។

១. ភាគីទាំងពីរបានឯកភាពជំរុញយន្តការកិច្ចពិគ្រោះយោបល់សន្តិសុខគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន ដើម្បីបង្កើនទំនាក់ទំនង និងការសម្របសម្រួលលើកិច្ចសហប្រតិបត្តិការសន្តិសុខទ្វេភាគី និងបញ្ហាសន្តិសុខដែលជាប្រយោជន៍រួម។ ភាគីទាំងពីរពង្រឹងការផ្លាស់ប្តូរ និងកិច្ចសហការប្រឆាំងនឹងការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ការបំបែករដ្ឋ និងបដិវត្តន៍ពណ៌ ដើម្បីធានារក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គមរបស់ប្រទេសទាំងពីរ។

២. ភាគីទាំងពីរបានឯកភាពប្រើប្រាស់ឱ្យពេញលេញនូវយន្តការកិច្ចសហប្រតិបត្តិការរវាងកងកម្លាំងប្រដាប់អាវុធ នៃប្រទេសទាំងពីរ រក្សាការផ្លាស់ប្តូរគ្រប់កម្រិត ធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការផ្នែកអប់រំ ហ្វឹកហ្វឺន ការធ្វើលំហាត់សមយុទ្ធរួម សេវាវេជ្ជសាស្ត្រនិងភស្តុភារ គ្រឿងបរិក្ខារ បច្ចេកវិទ្យា និងវិស័យផ្សេងៗ ព្រមទាំងជំរុញការសម្របសម្រួលក្នុងកិច្ចការសន្តិសុខពហុភាគី។ កម្ពុជាអរគុណភាគីចិន ដែលបានគាំទ្រដំណើរការរលូននៃ មជ្ឈមណ្ឌលភស្តុភារ និងហ្វឹកហ្វឺនរួមគ្នាកម្ពុជា-ចិន នៅកំពង់ផែរាម ដើម្បីជួយកម្ពុជាពង្រឹងសមត្ថភាពការពារអធិបតេយ្យភាព សន្តិសុខជាតិ និងផលប្រយោជន៍អភិវឌ្ឍន៍។

៣. ភាគីចិនកោតសរសើរកម្ពុជា ដែលបានប្រកាសបង្ក្រាបល្បែងស៊ីសងតាមប្រព័ន្ធអ៊ីនធឺណេតខុសច្បាប់ និងបង្កើតគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ តាមរយៈការបន្តអនុវត្តឆ្នាំ នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់កម្ពុជា-ចិន ភាគីទាំងពីរនឹងពង្រឹងការសម្របសម្រួល និងជំនួយសម្រាប់ការស៊ើបអង្កេតលើសំណុំរឿងឧក្រិដ្ឋកម្មឆ្លងដែនដូចជា ល្បែងឆ្លងដែនខុសច្បាប់ ការរត់ពន្ធមនុស្ស ការក្លែងបន្លំនិងការរត់ពន្ធ។ ភាគីទាំងពីរនឹងពង្រឹងកិច្ចសហប្រតិបត្តិការសន្តិសុខ និងតុលាការ និងពន្លឿនការចរចាដើម្បីចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគី ស្តីពីជំនួយផ្នែកច្បាប់ក្នុងសំណុំរឿងព្រហ្មទណ្ឌ ដើម្បីជំរុញការបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ ភាគីទាំងពីរនឹងពង្រឹងសុវត្ថិភាពរបស់ពលរដ្ឋកម្ពុជា និងចិននៅក្នុងប្រទេសរៀងៗខ្លួន ព្រមទាំងបង្កើនការការពារសុវត្ថិភាពនៃគម្រោងធំៗក្នុងក្របខណ្ឌនៃការអភិវឌ្ឍន៍ខ្សែក្រវាត់ និងផ្លូវ។

៤. ភាគីទាំងពីរបញ្ជាក់ជាថ្មីនូវសារៈសំខាន់នៃការរក្សាសន្តិភាព និងស្ថិរភាពក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ភាគីទាំងពីរប្រឆាំងចំពោះការប្រមូលផ្តុំបង្កើតក្រុមផ្តាច់មុខ ការប្រឈមមុខដាក់គ្នារវាងប្លុក ការរីកសាយ

អាវុធនុយក្លេអ៊ែរ និងការពង្រាយកាំជ្រួចនានា ដែលនឹងបង្កឱ្យមានការប្រណាំងប្រជែងសព្វាវុធ និងប៉ះពាល់ដល់សន្តិភាព និងស្ថិរភាពក្នុងតំបន់។ ភាគីទាំងពីរបានឯកភាពជំរុញការកសាងសហគមន៍វាសនារួមអាស៊ី-ប៉ាស៊ីហ្វិក ដើម្បីរួមចំណែកកាន់តែច្រើនដល់ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់នេះ។

៥. កម្ពុជាកោតសរសើរតួនាទីប្រកបដោយការស្ថាបនារបស់ចិនក្នុងការសម្របសម្រួលដំណោះស្រាយលើបញ្ហាក្ដៅនានាក្នុងតំបន់ និងអន្តរជាតិ។ ភាគីទាំងពីរបានឯកភាពពង្រឹងការសម្របសម្រួលនៅក្នុងក្របខណ្ឌពហុភាគី ដើម្បីរួមចំណែកជាមួយគ្នាចំពោះស្ថិរភាព និងសន្តិភាពពិភពលោក។

៦. ភាគីទាំងពីរចាត់ទុកជាភាពចាំបាច់ក្នុងការស្វែងយល់អំពីបរិបទជាក់ស្ដែងរបស់ប្រទេសនីមួយៗក្នុងការជ្រើសរើសមាគ៌ាអភិវឌ្ឍន៍សិទ្ធិមនុស្ស ដែលស្របតាមតម្រូវការរបស់ប្រជាជន។ ភាគីទាំងពីរប្រឆាំងយ៉ាងម៉ឺងម៉ាត់ចំពោះការធ្វើនយោបាយនីយកម្មលើបញ្ហាសិទ្ធិមនុស្ស ការអនុវត្តស្តង់ដាពីរ និងការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ឬការញុះញង់ឱ្យមានការបែកបាក់ និងការប្រឈមមុខដាក់គ្នា ដោយប្រទេសណាមួយ ក្រោមលេសសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ក្នុងគោលបំណងដាក់គំនាបលើប្រទេសដទៃ។

៧. កម្ពុជាវាយតម្លៃខ្ពស់ចំពោះប្រទេសចិនលើជំនួយផ្នែកហិរញ្ញវត្ថុ ការបណ្ដុះបណ្ដាល និងឧបករណ៍បោសសម្អាតមីនដល់កម្ពុជា ដើម្បីជួយកម្ពុជាឱ្យសម្រេចគោលដៅមិនទទួលរងផលប៉ះពាល់ពីមីននៅឆ្នាំ២០៣០។ ភាគីចិនបង្ហាញឆន្ទៈធ្វើការជាមួយកម្ពុជា ដើម្បីអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នាស្ដីពីកិច្ចសហប្រតិបត្តិការបោសសម្អាតមីន ដើម្បីជួយកម្ពុជាលុបបំបាត់ការគំរាមកំហែងដោយសារមីន តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី។

៨. ភាគីទាំងពីរនឹងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងឆ្លើយតបចំពោះគ្រោះអាសន្ន តាមរយៈការអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នាស្ដីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការឆ្លើយតបចំពោះគ្រោះអាសន្ន ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពជាតិក្នុងការបង្ការ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះអាសន្ន។ ភាគីទាំងពីរនឹងធ្វើឱ្យស៊ីជម្រៅភាពជាដៃគូ ផ្ដល់តួនាទីកាន់តែសំខាន់ដល់ក្របខណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃគំនិតផ្ដួចផ្ដើមខ្សែក្រវាត់ និងផ្លូវ សម្រាប់ការគ្រប់គ្រងគ្រោះអាសន្ន និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដើម្បីរួមគ្នាដោះស្រាយហានិភ័យនិងបញ្ហាប្រឈមបន្ទាន់នានា ពង្រឹងភាពធន់នៅក្នុងតំបន់ លើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងរួមចំណែកកសាងសហគមន៍វាសនារួមសម្រាប់មនុស្សជាតិ។

៩. ភាគីទាំងពីរយល់ថា បញ្ហាសមុទ្រចិនខាងត្បូងគួរត្រូវបានដោះស្រាយដោយសន្តិវិធី តាមរយៈការពិគ្រោះយោបល់ និងការចរចាប្រកបដោយមិត្តភាព រវាងរដ្ឋអធិបតេយ្យដែលពាក់ព័ន្ធផ្ទាល់ក្នុងបញ្ហានេះ។ រាល់ការប៉ុនប៉ងប្រើប្រាស់បញ្ហានេះ ក្នុងគោលដៅបំផ្លាញដល់សន្តិភាពតំបន់ និងការទុកចិត្តគ្នាទៅវិញទៅមក នឹងរងនូវផលវិបាកមកវិញ។ ភាគីទាំងពីរគូសបញ្ជាក់ពីសារៈសំខាន់នៃការរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាពនៅសមុទ្រចិនខាងត្បូង និងអំពាវនាវគ្រប់ភាគីពាក់ព័ន្ធបន្តអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពនូវសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូង និងធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការសមុទ្រ ព្រមទាំងសម្រេចឱ្យបានជាដុំកំភួន និងមានប្រសិទ្ធភាពនូវ ក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង ឱ្យបានឆាប់ស្របតាមគោលការណ៍កុងសង់ស៊ីស តាមរយៈការពិគ្រោះយោបល់។

## ការអនុវត្តគំនិតផ្តួចផ្តើមអរិយធម៌សកល (GCI)

ភាគីទាំងពីរបានគូសបញ្ជាក់ថា កម្ពុជានិងចិនគឺជាប្រទេសដែលមានអរិយធម៌បុរាណ និងមានប្រវត្តិសាស្ត្រយូរលង់។ ប្រទេសទាំងពីរជាប្រទេសលេចធ្លោក្នុងការគោរពភាពចម្រុះនៃអរិយធម៌ក្នុងពិភពលោក តម្លៃរួមនៃមនុស្សជាតិ បេតិកភណ្ឌវប្បធម៌ និងនវានុវត្តន៍ ព្រមទាំងបង្ហាញឆន្ទៈក្នុងការធ្វើជាគំរូសម្រាប់ការអនុវត្តគំនិតផ្តួចផ្តើមអរិយធម៌សកល ពង្រឹងការផ្លាស់ប្តូរវប្បធម៌ និងប្រជាជនក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី ដើម្បីសម្រួលដល់ការផ្លាស់ប្តូរ និងការស្វែងយល់ពីគ្នាទៅវិញទៅមកក្នុងចំណោមអរិយធម៌នានា។

១. ភាគីចិនអរគុណកម្ពុជា ដែលបានគាំទ្រសេចក្តីសម្រេចចិត្តស្តីពីការបង្កើតទិវាអន្តរជាតិសម្រាប់ការសន្ទនាក្នុងចំណោមអរិយធម៌នានា និងចូលរួមជាសមាជិកស្នូលក្នុងក្រុមប្រទេសនាំមុខនៃសេចក្តីសម្រេចចិត្តខាងលើ។ ភាគីកម្ពុជាសរសើរចំពោះសន្និសីទស្តីពីកិច្ចសន្ទនានៃអរិយធម៌អាស៊ី ដែលរៀបចំដោយប្រទេសចិន និងយល់ថា សន្និសីទនេះដើរតួនាទីសំខាន់ក្នុងការជំរុញការផ្លាស់ប្តូរវប្បធម៌ក្នុងចំណោមប្រទេសនានា។ កម្ពុជាមានឆន្ទៈរួមគ្នាពង្រឹងកិច្ចសន្ទនាក្នុងចំណោមអរិយធម៌នានា ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរ និងការស្វែងយល់ពីគ្នាទៅវិញទៅមក ក្នុងចំណោមអរិយធម៌អាស៊ី។

២. កម្ពុជាស្វាគមន៍សកម្មភាពរីករាយបុណ្យចូលឆ្នាំចិន ដែលប្រារព្ធដោយភាគីចិននៅកម្ពុជា។ ភាគីទាំងពីរនឹងជំរុញឱ្យបន្តដំណើរការឡើងវិញនៃមជ្ឈមណ្ឌលវប្បធម៌ចិននៅទីក្រុងភ្នំពេញ និងគាំទ្រការចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីសិល្បៈ ការផ្លាស់ប្តូរ និងការសម្តែងអន្តរជាតិ ដែលរៀបចំនៅប្រទេសរៀងៗខ្លួន។

៣. ភាគីទាំងពីរវាយតម្លៃខ្ពស់អំពីសកម្មភាពក្នុងឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជនកម្ពុជា-ចិន ២០២៤ និងឯកភាពកំណត់យក**ឆ្នាំ២០២៥ ជាឆ្នាំទេសចរណ៍កម្ពុជា-ចិន** ហើយលើកទឹកចិត្តប្រជាពលរដ្ឋទាំងពីរឱ្យធ្វើដំណើរកម្សាន្តទៅវិញទៅមក។ ភាគីទាំងពីរនឹងរួមគ្នាអភិវឌ្ឍផ្លូវទេសចរណ៍ លើកកម្ពស់វិស័យទេសចរណ៍ ពង្រឹងកិច្ចសហប្រតិបត្តិការសុវត្ថិភាពទេសចរណ៍ និងលើកកម្ពស់សមត្ថភាពជំនាញមគ្គុទ្ទេសក៍

ទេសចរណ៍ តាមរយៈការបង្កើនកម្មវិធីបណ្តុះបណ្តាល។ ទិដ្ឋាការមេគង្គ-ឡានឆាង ដែលដាក់ចេញដោយប្រទេសចិននៅខែវិច្ឆិកា ឆ្នាំ២០២៤ នឹងជួយសម្រួលដល់ការធ្វើដំណើររវាងប្រទេសទាំងពីរ។ ភាគីទាំងពីរនឹងគាំទ្រអាកាសចរណ៍ដឹកអ្នកដំណើរ និងដឹកទំនិញ ឱ្យបង្កើនជើងហោះហើរញឹកញាប់ និងបង្កើតផ្លូវហោះហើរថ្មីរវាងកម្ពុជា និងចិន តាមតម្រូវការទីផ្សារ។

៤. ភាគីចិនកោតសរសើរកម្ពុជាក្នុងការចូលរួមផ្តួចផ្តើមបង្កើតសម្ព័ន្ធដើម្បីបេតិកភណ្ឌវប្បធម៌នៅអាស៊ី ដែលកម្ពុជាបានដើរតួនាទីជាវិជ្ជមានលើកិច្ចការនេះ។ ភាគីទាំងពីរនឹងពិនិត្យលទ្ធភាពបង្កើតក្រុមការងារចម្រុះកម្ពុជា-ចិនស្តីពីបេតិកភណ្ឌវប្បធម៌ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យនេះ។ ភាគីទាំងពីរនឹងពង្រឹងកិច្ចខិតខំប្រឹងប្រែងជំរុញកម្មវិធីអភិរក្ស និងស្តារព្រះបរមរាជវាំងបុរាណនៅអង្គរ និងសហការអភិរក្សប្រាសាទព្រះវិហារ និងបេតិកភណ្ឌវប្បធម៌ដទៃទៀត។ កម្ពុជាថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រយ៉ាងមុឹងម៉ាត់របស់ចិនក្នុងវិស័យវប្បធម៌ ដោយបានពង្រឹងការប្តេជ្ញាចិត្តរួមគ្នាក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌ ការលើកកម្ពស់ការផ្លាស់ប្តូរវប្បធម៌ និងការជំរុញការយល់ដឹងកាន់តែស៊ីជម្រៅរវាងប្រជាជននៃប្រទេសទាំងពីរ។

៥. ភាគីទាំងពីរនឹងពង្រឹងកិច្ចសន្ទនាលើគោលនយោបាយអប់រំ ពិភាក្សាអំពីការបន្តសុពលភាព នៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំ និងធ្វើឱ្យស៊ីជម្រៅកិច្ចសហការក្នុងវិស័យនេះ ដូចជាការបង្រៀនភាសាចិន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំឌីជីថល។ ភាគីកម្ពុជាគាំទ្រវិទ្យាស្ថានខុងជឺ និងវិទ្យាស្ថានអប់រំដទៃទៀតក្នុងការបង្រៀនភាសាចិន ហើយភាគីចិននឹងបន្តផ្តល់អាហារូបករណ៍រដ្ឋាភិបាលចិន និងអាហារូបករណ៍គ្រូបង្រៀនភាសាចិនអន្តរជាតិដល់កម្ពុជា។ ភាគីទាំងពីរក៏ប្រឹងប្រែងអនុវត្តកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនានារួមមាន សិក្ខាសាលាលូប៉ាន ការជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យអប់រំ និងការបង្កើនអ្នកបច្ចេកទេសពហុជំនាញបន្ថែមទៀត។

៦. ភាគីទាំងពីរនឹងអនុវត្តកិច្ចព្រមព្រៀងនានាស្តីពីកិច្ចសហប្រតិបត្តិការការងារ និងរបបសន្តិសុខសង្គម និងពង្រឹងកិច្ចសហការក្នុងការលើកកម្ពស់ការងារ និងសហគ្រិនភាព បង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធរបបសន្តិសុខសង្គម។

៧. ភាគីទាំងពីរបានឯកភាពធ្វើឱ្យស៊ីជម្រៅនូវការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការក្នុងវិស័យឱសថបុរាណ ការគ្រប់គ្រងវេជ្ជសាស្ត្រ ការបណ្តុះបណ្តាលបុគ្គលិកវេជ្ជសាស្ត្រ ការគ្រប់គ្រងជំងឺ ការសង្គ្រោះបន្ទាន់ផ្នែកសុខាភិបាល និងវិស័យពាក់ព័ន្ធនឹងសុខាភិបាល។ ភាគីទាំងពីរនឹងពិនិត្យលទ្ធភាពដាក់ឱ្យប្រើប្រាស់នូវមជ្ឈមណ្ឌលកម្ពុជាសម្រាប់គ្រប់គ្រង និងបង្ការជំងឺ និងជំរុញវឌ្ឍនភាពនៃការបង្កើតមជ្ឈមណ្ឌលឱសថ

បុរាណចិននៅកម្ពុជា។ ភាគីចិនត្រៀមខ្លួនជាស្រេចក្នុងការបញ្ជូនក្រុមគ្រូពេទ្យចិនបន្ថែមមកកម្ពុជា និង អនុវត្តកម្មវិធីព្យាបាលភ្នែកនៅកម្ពុជា។

៨. ភាគីទាំងពីរបានឯកភាពជំរុញការផ្លាស់ប្តូរជាទៀងទាត់រវាងនាយកដ្ឋានកិច្ចការយុវជន និងសហភាពយុវជន នៃប្រទេសទាំងពីរ បង្កើតផ្ទះមិត្តភាពយុវជនកម្ពុជា-ចិន ព្រមទាំងបង្កើតយន្តការសន្ទនា និងផ្លាស់ប្តូររវាងយុវជន ដើម្បីជំរុញកម្លាំងថ្មីសម្រាប់ចំណងមិត្តភាពរវាងកម្ពុជា និងចិន។

៩. ភាគីទាំងពីរបានឯកភាពធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការរវាងធនាគារខួរក្បាល ទីក្រុងសម្ព័ន្ធមេត្រីភាព សាសនា ក្រុមជនជាតិភាគតិច និងអង្គការមិនមែនរដ្ឋាភិបាល។ ភាគីទាំងពីរឯកភាពបន្តរៀបចំវេទិកាធនាគារខួរក្បាលកម្រិតខ្ពស់កម្ពុជា-ចិន និងលើកទឹកចិត្តឱ្យបង្កើនការចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលជនជាតិភាគតិច ហើយគាំទ្រឱ្យអង្គការមិនមែនរដ្ឋាភិបាលនៃប្រទេសទាំងពីរពង្រឹងកិច្ចសហប្រតិបត្តិការ។

១០. ភាគីទាំងពីរលើកទឹកចិត្តស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ សារព័ត៌មាន បោះពុម្ពផ្សាយ វិទ្យុ ភាពយន្ត និងទូរទស្សន៍ក្នុងប្រទេសទាំងពីរ ឱ្យពង្រឹងកិច្ចសហប្រតិបត្តិការគ្នា។ ភាគីទាំងពីរបានឯកភាពអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការវិទ្យុ និងទូរទស្សន៍ ព្រមទាំងបន្តជំរុញការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការលើបច្ចេកវិទ្យាផ្សាយនិងសោតទស្សន៍ ឧស្សាហកម្ម មាតិកា និងការបណ្តុះបណ្តាលធនធានមនុស្ស។

ក្នុងអំឡុងពេលទស្សនកិច្ច ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការរួមមាន ខ្សែច្រវាក់ផ្គត់ផ្គង់ និងឧស្សាហកម្ម បញ្ញាសិប្បនិម្មិត ជំនួយអភិវឌ្ឍន៍ ការត្រួតពិនិត្យផ្នែកគយនិងចត្តាឡីស័ក សុខាភិបាល និងកិច្ចការសារព័ត៌មាន។

ក្នុងការអបអរសាទរចំពោះលទ្ធផលផ្លែផ្កានៃដំណើរទស្សនកិច្ចដ៏សំខាន់របស់**ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** ភាគីទាំងពីរជឿជាក់ថា ទស្សនកិច្ចនេះមានសារៈសំខាន់ខ្លាំងសម្រាប់ការពង្រឹងទំនាក់ទំនងមិត្តភាពជាប្រពៃណីកម្ពុជា-ចិន និងជំរុញការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន គ្រប់រដូវកាល ក្នុងយុគសម័យថ្មី។

**ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** បានថ្លែងអំណរគុណកម្ពុជាចំពោះការផ្តល់បដិសណ្ឋារកិច្ចដ៏កក់ក្តៅ និងរាក់ទាក់។ **ឯកឧត្តម**ក៏បានអញ្ជើញថ្នាក់ដឹកនាំកម្ពុជាទៅបំពេញទស្សនកិច្ចនៅប្រទេសចិន នាពេលវេលាសមស្រប ហើយថ្នាក់ដឹកនាំកម្ពុជាបានទទួលយកការអញ្ជើញនេះដោយក្តីសោមនស្សរីករាយ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៥